

# តើស្ដេចបេនយ៉ាមីនជានរណា ?

ស្ដេចបេនយ៉ាមីន ជាព្យាការីរបស់ព្រះ និងជាស្ដេចសុចរិត ។ ទ្រង់បានប្រមូលប្រជារាស្ត្ររបស់ទ្រង់ដើម្បីបង្រៀនពួកគេ ។ ទ្រង់បានគង់នៅលើប៉មមួយ ដើម្បីឲ្យប្រជាជនអាចស្ដាប់ឮទ្រង់កាន់តែច្បាស់ ។ ប្រជាជនបោះតង់នៅជុំវិញប៉មដើម្បីស្ដាប់ ។ វាដូចជាសន្និសីទទូទៅដូច្នោះដែរ !



ស្ដេចបេនយ៉ាមីនបានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទនឹងប្រសូតនៅលើផែនដី ។ ព្រះយេស៊ូវនឹងធ្វើអព្ភូតហេតុ ។ ទ្រង់នឹងរងទុក្ខ ហើយសុគតសម្រាប់អំពើបាបរបស់មនុស្សទាំងអស់ ។ បន្ទាប់មក ទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ ដើម្បីឲ្យយើងទាំងអស់គ្នាអាចរស់ឡើងវិញបាន !



ស្ដេចបេនយ៉ាមីនបានអញ្ជើញប្រជាជនឲ្យទទួលយកព្រះនាមនៃព្រះគ្រីស្ទ ។ នោះមានន័យថាពួកគេបានចុះសេចក្ដីសញ្ញា ឬការសន្យាមួយដើម្បីធ្វើតាមព្រះ ហើយកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ។



សព្វថ្ងៃនេះ យើងបង្ហាញថាយើងស្ម័គ្រចិត្តទទួលយកព្រះនាមព្រះគ្រីស្ទ មកដាក់លើខ្លួនយើង ពេលយើងទទួលបុណ្យជ្រមុជទឹក ។ ●

## ការសាកល្បងព្រះគម្ពីរ

បន្ទាប់ពីប្រជាជនបានស្ដាប់ស្ដេចបេនយ៉ាមីន តើពួកគេបានចុះសេចក្ដីសញ្ញាជាមួយនរណា ? ( ម៉ូសាយ ៥:៥ )

______________________

តើអ័ប៊ីណាដៃទូលស្ដេចណូអេថាទ្រង់ត្រូវធ្វើអ្វីខ្លះ ដើម្បីបានសង្គ្រោះ ? ( ម៉ូសាយ ១២:៣៣ )

______________________

បន្ទាប់ពីអាលម៉ា និងហេឡាមបានចេញពីទឹក តើពួកគាត់ពោរពេញទៅដោយអ្វី ? ( ម៉ូសាយ ១៨:១៤ )

______________________

## ខ្ញុំចេះអានព្រះគម្ពីរមរមន !

បន្ទាប់ពីប្អូនអាន សូមផាត់ពណ៌រូបភាពនេះ ។ អ្នកអាចអានខគម្ពីរទាំងនេះដែលស្របទៅនឹងអំណានប្រចាំសប្ដាហ៍នីមួយៗមកពី *ចូរមកតាមខ្ញុំ* ។

សប្ដាហ៍ទី ១ ៖ ម៉ូសាយ ៤:៩

សប្ដាហ៍ទី ២ ៖ ម៉ូសាយ ៧:១៩

សប្ដាហ៍ទី ៣ ៖ ម៉ូសាយ ១៦:៩

សប្ដាហ៍ទី ៤ ៖ ម៉ូសាយ ១៨:៨–១០



សូមធ្វើអ្វីមួយដែលរំឭកអ្នកអំពីអ្វីដែលព្យាការីរបស់ព្រះអម្ចាស់បានបង្រៀន ។ ចែកចាយអ្វីដែលប្អូនបានធ្វើជាមួយយើង !

ចម្លើយ ៖ ព្រះ គោរពតាមបទបញ្ញត្តិ ព្រះវិញ្ញាណ

រចនារូបភាពដោយ ស៊ីមីនី ប្លូកយើរ